# សេចក្តីជូនដំណឹង

អង្គការ សមាគមក្រៅរដ្ឋាភិបាល មានកិត្តិយលជម្រាបជូនដំណឹង និងគោរពអញ្ជើញលោក លោកស្រី អ្នកនាង កញ្ញា ដែលជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា ក្រុមអង្គការ សមាគមក្រៅរដ្ឋាភិបាល រួមមាន គណៈកម្មការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជ មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា សមាគមយុវជនខ្មែរ អង្គការយុវជន និងកុមារដើម្បីសេរីភាព និងអង្គការសភាយុវជនខ្មែរនឹងរៀបចំ**វេទិកាយុវជន**ស្តីពី"**ការជ្រើសរើសសមាជិកគណៈកម្មការជាតិរៀបចំបោះឆ្នោត** (**គ.ជ.ប**) **ថ្មី**"។

**វេទិកាយុវជននេះរៀបចំឡើងក្នុងគោលបំណង៖**

១. ពិភាក្សា និងផ្តល់យោបល់អំពីលក្ខណៈវិនិច្ឆ័យ និងលក្ខណៈសម្បត្តិរបស់សមាជិក គ.ជ.ប ថ្មី។

២. ពិភាក្សា និងផ្តល់យោបល់អំពីការបើកទូលាយឱ្យសាធារណៈជនពិនិត្យ និងវាយតម្លៃបេក្ខជន ដែលជាសមាជិក គ.ជ.ប ថ្មី មុនការផ្តល់សេចក្តីទុកចិត្តដោយរដ្ឋសភា។

៣. រៀបចំញត្តិស្តីពីជំហររបស់ក្រុមយុវជនលើលក្ខណៈវិនិច្ឆ័យ និងលក្ខណៈសម្បត្តិរបស់សមាជិក គ.ជ.ប ថ្មី និងការបើកទូលាយឱ្យសាធារណៈជនពិនិត្យ និងវាយតម្លៃបេក្ខជនដែលជាសមាជិក គ.ជ.ប ថ្មី មុនការផ្តល់សេចក្តីទុកចិត្តដោយរដ្ឋ។

**កាលបរិច្ឆេទ៖** ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ (រយៈពេលមួយព្រឹក)
**ទីកន្លែង៖** សាលប្រជុំ អង្គការអភិវឌ្ឍន៍ធនធានយុវជន (YRDP) អាសយដ្ឋានៈ ផ្ទះលេខ៩៣ ផ្លូវលេខ៥៩០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

អាស្រ័យដូចបានជម្រាបជូនខាងលើ អង្គការ សមាគមក្រៅរដ្ឋាភិបាលយើងខ្ញុំ សូមគោរពអញ្ជើញអស់លោក លោកស្រី អ្នកនាង កញ្ញា ដែលជាអ្នកសារព័ត៌មានទាំងអស់មេត្តាជ្រាប និងចូលរួមយកព័ត៌មានកុំបីខាន។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**
លោក **ស៊ិន ទិត្យសីហា** តាមរយៈ
ទូរស័ព្ទៈ ០១២ ២៥ ២៦ ៦១ ឬ
អ៊ីម៉ែលៈ seiha@comfrel.org